# ដឹងពីសិទ្ធិបោះឆ្នោតរបស់អ្នកនៅខោនធី Santa Clara

ការបោះឆ្នោតសកលឆ្នាំ 2020 នៅរដ្ឋ California

ASIAN AMERICANS ADVANCING JUSTICE ASIAN LAW CAUCUS

សន្លឹកឆ្នោតដែលត្រូវផ្ញើទៅឲ្យអ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយទាំងអស់៖ **ចាប់ផ្តើមពីថ្ងៃទី 5 ខែតុលា ឆ្នាំ 2020**
ប្រអប់បោះឆ្នោតបើក៖ **ថ្ងៃច័ន្ទ ទី 5 ខែតុលា ឆ្នាំ 2020**
ថ្ងៃផុតកំណត់ចុះឈ្មោះ៖ **ថ្ងៃច័ន្ទ ទី 19 ខែតុលា ឆ្នាំ 2020**
មណ្ឌលបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់៖ **ថ្ងៃសៅរ៍ ទី 31 ខែតុលា ឆ្នាំ 2020 - ថ្ងៃអង្គារទី 3 ខែវិច្ឆិកា ឆ្នាំ 2020**
ការិយាល័យបោះឆ្នោតខោនធី Santa Clara៖ 866-430-VOTE (8683)

## ការត្រៀមខ្លួនបោះឆ្នោត

ដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោត
ជាដំបូងអ្នកត្រូវចុះឈ្មោះបោះឆ្នោតជាមុនសិន! អ្នកអាចចុះឈ្មោះបាន ប្រសិនបើអ្នកគឺជា៖

- ពលរដ្ឋអាមេរិក
- អ្នករស់នៅរដ្ឋ California
- មានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្ននេះ មិននៅក្នុងពន្ធនាគារ ឬស្ថិតក្នុងរយៈពេលដោះលែងមុនកំណត់មានលក្ខខណ្ឌចំពោះការដាក់ទោសពីបទឧក្រិដ្ឋអ្វីមួយ និង
- មិនត្រូវបានតុលាការរកឃើញថា "អសមត្ថភាពផ្លូវចិត្ត"

<u>បានចុះឈ្មោះរួចហើយឬ?</u>

ពិនិត្យនិងធ្វើបច្ចុប្បន្នភាពព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក។ ប្រើ voterstatus.sos.ca.gov ដើម្បី៖

✓ បញ្ជាក់អាសយដ្ឋានផ្ញើសំបុត្ររបស់អ្នក
✓ បន្ថែម ឬធ្វើបច្ចុប្បន្នភាពអាសយដ្ឋានអ៊ីមែលដើម្បីទទួលបានព័ត៌មានទាន់ពេលវេលាពីការិយាល័យបោះឆ្នោតនៃខោនធីរបស់អ្នក
✓ សូមប្រាប់អំពីភាសាដែលអ្នកចូលចិត្ត ដើម្បីទទួលបានឯកសារបកប្រែ ប្រសិនបើវាមាននៅក្នុងតំបន់របស់អ្នក

អ្នកក៏អាចធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកដោយប្រើទម្រង់បែបបទស្នើសុំសកម្មភាពរបស់អ្នកបោះឆ្នោតនៅ Santa Clara ដែលមាននៅលើវិបសាយនៃការិយាល័យបោះឆ្នោតខោនធី។

<u>ចង់ចុះឈ្មោះឬ?</u>

រហូតដល់**ថ្ងៃច័ន្ទ ទី 19 ខែតុលា** អ្នកអាចចុះឈ្មោះ៖

- តាមអ៊ីនធឺណិត registertovote.ca.gov
- នៅឯ DMV, ការិយាល័យប្រៃសណីយ៍ បណ្ណាល័យ ឬនៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬ
- ដោយទូរស័ព្ទទៅការិយាល័យបោះឆ្នោតខោនធីតាមលេខ 1-866-430-VOTE (8683) ដើម្បីស្នើសុំទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត ដែលត្រូវផ្ញើតាមសំបុត្រមិនហួសពីថ្ងៃទី 19 ខែតុលា។ មិនចាំបាច់បិទតែមទេ!

<u>តើធ្វើដូចម្តេច ប្រសិនបើខ្ញុំខកខានហួសថ្ងៃផុតកំណត់ចុះឈ្មោះអ្នកបោះឆ្នោត?</u>

គ្មានបញ្ហាទេ! អ្នកនៅតែអាចចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃណាមួយក៏បានរហូតដល់ និងរួមទាំងថ្ងៃបោះឆ្នោត។
ជម្រើសទី 1៖ អ្នកអាចទៅកាន់ការិយាល័យបោះឆ្នោតខោនធី ឬមណ្ឌលបោះឆ្នោតណាមួយក្នុងខោនធីរបស់អ្នកដើម្បីប្រើប្រាស់ "ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ" ដើម្បីចុះឈ្មោះ និងបោះឆ្នោតពេលនោះតែម្តង។
អ្នកនឹងទទួលបានទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត និងសន្លឹកឆ្នោតដើម្បីបំពេញនៅនឹងកន្លែង។

ជម្រើសទី 2៖ ប្រសិនបើអ្នកមិនបានចុះឈ្មោះបោះឆ្នោត ហើយមិនអាចទៅកាន់ការិយាល័យបោះឆ្នោត ឬមណ្ឌលបោះឆ្នោតបានទេ សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីដើម្បីសួរពីរបៀបដែលអាចឲ្យអ្នកចុះឈ្មោះ និងបោះឆ្នោតបានពីចម្ងាយដោយប្រើ "ការបោះឆ្នោតតាមសំបុត្រដែលអាចដំណើរការពីចម្ងាយបាន"។

ASIAN AMERICANS ADVANCING JUSTICE ASIAN LAW CAUCUS

# តើត្រូវបោះឆ្នោតដូចម្តេច? មានច្រើនជម្រើស!

## បោះឆ្នោតពីផ្ទះ

ប្រសិនបើអ្នកចុះឈ្មោះមុនឬនៅថ្ងៃទី 19 ខែតុលា អ្នកនឹងទទួលបានដោយស្វ័យប្រវត្តិនូវសន្លឹកឆ្នោតដែលផ្ញើតាម**សំបុត្រ**ជាមួយនឹងសេចក្តីណែនាំអំពីរបៀបបំពេញ និងរបៀបផ្ញើមកវិញ។ អ្នកអាច៖

1. ផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ -- មិនចាំបាច់បិទតែមទេ!
    - កុំភ្លេចចុះហត្ថលេខា និងកាលបរិច្ឆេទលើស្រោមសន្លឹកឆ្នោតរបស់អ្នកផង។
    - ត្រូវប្រាកដថា បានបិទស្លាកប្រៃសណីយ៍លើសន្លឹកឆ្នោតរបស់អ្នករួចហើយនៅ ឬមុនថ្ងៃបោះឆ្នោត។
2. សូមបោះវាចូលទៅក្នុង "ប្រអប់បោះឆ្នោត" ផ្លូវការណាមួយ ដែលមានជាច្រើននៅពាសពេញខោនធី ឬនៅឯមណ្ឌលបោះឆ្នោត -- សូមរំឭកម្តងទៀតថា មិនចាំបាច់បិទតែមទេ! មានប្រអប់បោះឆ្នោតដែលមានសុវត្ថិភាព 24 ម៉ោង ដែលនឹងបើកចាប់ពីថ្ងៃទី 5 ខែតុលា រហូតដល់ម៉ោង 8 យប់ ថ្ងៃទី 3 ខែវិច្ឆិកា។ សូមទៅកាន់វិបសាយ eservices.sccgov.org/rov/ ដើម្បីស្វែងរកមណ្ឌលបោះឆ្នោត និងប្រអប់បោះឆ្នោតដែលនៅជិតទីតាំងរបស់អ្នក។

## បោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់

ប្រសិនបើអ្នកចង់ទៅបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ ក៏បាន! ការបោះឆ្នោតមុនពេលកំណត់ និងការចុះឈ្មោះក្នុងថ្ងៃតែមួយ មាននៅតាមការិយាល័យបោះឆ្នោតខោនធីរបស់អ្នក និងនៅតាមមណ្ឌលបោះឆ្នោតនានា។

ការិយាល័យបោះឆ្នោតខោនធី Santa Clara ស្ថិតនៅ 1555 Berger Drive Building 2, San Jose, CA 95112។ វាបើកទ្វារបោះឆ្នោត៖
ច័ន្ទ-សុក្រ ពីថ្ងៃទី 5 ខែតុលា ដល់ថ្ងៃទី 2 ខែវិច្ឆិកា៖ ម៉ោង 8:00 ព្រឹក - 5:00 ល្ងាច
សៅរ៍-អាទិត្យ ថ្ងៃទី 24 - 25 ខែតុលា និងថ្ងៃទី 31 ខែតុលា - ថ្ងៃទី 1 ខែវិច្ឆិកា៖ ម៉ោង 8:00 ព្រឹក - 5:00 ល្ងាច
ថ្ងៃ 3 ខែវិច្ឆិកា៖ ម៉ោង 7:00 យប់ - 8:00 យប់

ឬអ្នកអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធីក៏បាន។ មណ្ឌលបោះឆ្នោតនឹងបើកពី**ថ្ងៃសៅរ៍ ទី 31 ខែតុលា ឆ្នាំ 2020 រហូតដល់ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ អ្នកនឹងទទួលបានព័ត៌មានអំពីម៉ោង និងទីតាំងមណ្ឌលបោះឆ្នោតតាមរយៈសំបុត្រ ឬអ្នកអាចចូលទៅវិបសាយ eservices.sccgov.org/rov/ ដើម្បីស្វែងរកមណ្ឌលបោះឆ្នោតដែលនៅជិតទីតាំងរបស់អ្នក។

នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងបើកពី**ម៉ោង 7 ព្រឹកដល់ម៉ោង 8 យប់។** *ឲ្យតែអ្នកបានតម្រង់ជួរនៅមុនឬត្រឹមម៉ោង 8 យប់ នោះអ្នកនឹងអាចបោះឆ្នោតបាន។*

ដើរចូលមណ្ឌលបោះឆ្នោតណាមួយ រួចហើយផ្តល់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកឲ្យពួកគេដើម្បីទទួលបានសន្លឹកឆ្នោត។ ប្រសិនបើអ្នកចូលចិត្តបោះឆ្នោតជាភាសាមិនមែនអង់គ្លេស សូមសួរមើលថា តើពួកគេមានឯកសារជាភាសាអ្នកទេ ហើយតើមានបុគ្គលិកណាម្នាក់នៃមណ្ឌលបោះឆ្នោតចេះនិយាយភាសាអ្នកទេ។

<u>តើនឹងមានការការពារសុខភាពសាធារណៈដែរឬទេ?</u>

មាន។ បុគ្គលិកនៃមណ្ឌលបោះឆ្នោតនឹងពាក់ម៉ាស់ ហើយធ្វើតាមគោលការណ៍ណែនាំអំពីសុខភាពសាធារណៈ ព្រមទាំងនឹងរៀបចំមណ្ឌលបោះឆ្នោតឲ្យមានគម្លាតរវាងមនុស្សម្នាក់ៗ។ អ្នកបោះឆ្នោតត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវអំពីសុខភាពសាធារណៈរបស់រដ្ឋ និងមូលដ្ឋានដែលមានដូចជាការពាក់ម៉ាស់ និងការរក្សាគម្លាតពីគ្នា។

<u>តើខ្ញុំត្រូវបង្ហាញអត្តសញ្ញាណបណ្ណរបស់ខ្ញុំនៅពេលបោះឆ្នោតឬទេ?</u>

ស្ទើរតែគ្រប់ករណីទាំងអស់ គឺមិនបាច់ទេ។ អ្នកគ្រាន់តែត្រូវបង្ហាញឯកសារប៉ុណ្ណោះប្រសិនបើអ្នកធ្វើការបោះឆ្នោតជាលើកដំបូង ហើយអ្នកមិនបានបញ្ចូលលេខបណ្ណបើកបរ លេខអត្តសញ្ញាណបណ្ណរដ្ឋ ឬលេខរបបសន្តិសុខសង្គមនៅពេលអ្នកបានចុះឈ្មោះបោះឆ្នោតទេនោះ។ ក្នុងករណីនេះ ឯកសារជាច្រើននឹងប្រើការបាន។ សូមទូរស័ព្ទទៅការិយាល័យបោះឆ្នោតរបស់អ្នកជាមុនសិន ប្រសិនបើអ្នកមានការព្រួយបារម្ភអ្វីមួយ។

<u>តើខ្ញុំអាចឲ្យនរណាម្នាក់ជួយខ្ញុំធ្វើការបោះឆ្នោតបានទេ?</u>

បាន។ ច្បាប់ California អនុញ្ញាតឲ្យអ្នកមានមនុស្សរហូតដល់ទៅពីរនាក់ដើម្បីជួយអ្នកធ្វើការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ ឲ្យតែពួកគេមិនតំណាងឲ្យនិយោជក ឬសហជីពរបស់អ្នក។ ឲ្យសមាជិកគ្រួសារ ឬមិត្តភក្តិជួយបាន។

## តើធ្វើដូចម្តេចបើខ្ញុំមានបញ្ហានៅពេលបោះឆ្នោត?

កុំបោះបង់! **សូមស្នើសុំប្រើការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ**
ដើម្បីចុះឈ្មោះឡើងវិញ និងបោះឆ្នោត។
ប្រសិនបើអ្នកមិនអាចធ្វើដូច្នោះបានដោយសារហេតុផលណាមួយ
**សូមស្នើសុំសន្លឹកឆ្នោតបណ្តោះអាសន្ន**
ដែលជាសន្លឹកឆ្នោតដែលនឹងត្រូវរាប់នៅក្រោយថ្ងៃបោះឆ្នោត
ប្រសិនបើមន្ត្រីរៀបចំការបោះឆ្នោតបញ្ជាក់ថា
អ្នកមានសិទ្ធិទទួលបានមែន។

ឬទូរស័ព្ទទៅលេខទូរស័ព្ទទាន់ហេតុការណ៍អំពីកិច្ចការពារអ្នកបោះឆ្នោត

នៅថ្ងៃបោះឆ្នោត៖

866-OUR-VOTE (866-687-8683) សម្រាប់ជំនួយជាភាសាអង់គ្លេស។

888-API-VOTE (888-274-8683) សម្រាប់ជំនួយជាភាសាអង់គ្លេស

ចិនកុងងឺ ចិនកាតាំង វៀតណាម កូរ៉េ បេងហ្គាល់ អ៊ីរឌូ ហ៊ីនឌី

និងតាហ្គាឡុក។

888-Ve-Y-Vota (888-839-8682)

ទូរស័ព្ទទាន់ហេតុការណ៍ពីរភាសាអង់គ្លេស-អេស្ប៉ាញឥតគិតថ្លៃនៃមូលនិ

ធិអប់រំ NALEO។

## <u>តើខ្ញុំអាចបោះឆ្នោតជាភាសាផ្សេងក្រៅពីអង់គ្លេសបានឬទេ?</u>

បាន! ប្រសិនបើអ្នកចង់បោះឆ្នោតជាភាសាខ្មែរ ចិន តាហ្គាឡុក ហ៊ីនឌី
ជប៉ុន កូរ៉េ អេស្ប៉ាញ ឬវៀតណាម
យើងមានសន្លឹកឆ្នោតបកប្រែហើយដែលអ្នកអាចបោះឆ្នោតបាន។
ប្រសិនបើអ្នកនិយាយភាសានេប៉ាល់ ហ្គូចារ៉ាត ពុនចាប៊ី តាមិល
និងតេលូហ្គូ យើងអាចនឹងមានសន្លឹកឆ្នោត “ជាទូរសារ”
ដែលបកប្រែហើយ។

ប្រសិនបើអ្នកបោះឆ្នោតពីផ្ទះ ហើយចង់បានសន្លឹកឆ្នោតដែលបានបកប្រែ
ឬឯកសារផ្សេងទៀត សូមទូរស័ព្ទទៅការិយាល័យបោះឆ្នោតតាមលេខ
866-430-VOTE (8683)
ហើយស្នើសុំពួកគេផ្ញើសន្លឹកឆ្នោតដែលបានបកប្រែហើយមកឲ្យអ្នក។

ប្រសិនបើអ្នកបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់
សូមសួររកសន្លឹកឆ្នោតដែលបានបកប្រែហើយពីបុគ្គលិកនៃមណ្ឌលបោះ
ឆ្នោត។
អាចមានមន្ត្រីរៀបចំការបោះឆ្នោតដែលនិយាយពីរភាសាជួយអ្នកបាន។

អ្នកអាចរកមើលឯកសារចែកឥតគិតថ្លៃស្តីពីសិទ្ធិប្រើភាសាក្នុងការបោះឆ្នោ
ត ដែលពន្យល់បន្ថែមនៅលើវិបសាយ៖

advancingjustice-alc.org/know-your-voting-rights/។

អាស៊ីអាមេរិកជំរុញយុត្តិធម៌ - ក្រុមប្រជុំច្បាប់អាស៊ី
55 Columbus Avenue, San Francisco, CA 94111
ទូរស័ព្ទ (415) 896-1701
www.advancingjustice-alc.org